ដានីកណ្ដៀតកាតាបដើរចេញ ហើយបង្អើរពាក្យថា ÷

- ថ្ងៃនេះ ជួបក្មេងឆ្កួតម្នាក់និយាយកុំឱ្យដឹងខ្យល់អី ! ណ្ហើយ កុំប្រកាន់អី ធ្វើម៉េចនៅក្មេងៗ វាតែងតែដើរជេរចាស់ៗមិនស្គាល់ងាប់ទៅចុះនរក ៧ ជាន់ !

ពណ្ណរាយចាប់កាំភ្លើងជ័ររបស់វាញាត់គ្រាប់ហើយស្រេច វាគិតថាអោយតែដានីស្ទុះហេមកក្រញីវា វានឹងបាញ់អោយចំថ្ងាសនាងកន្ទួលអោយណាណី ដើម្បីកុំអោយដានីមាក់ងាយថាក្មេងជាងនាង ។

ឯដានីវិញវាគិតថា ÷

"អាមួយនេះដូចជាមុខក្រហមខ្លាំងណាស់ ប៉ាអញប្រាប់ថា កាលណាគេខឹងខ្លាំង សូម្បីតែដែកក៏គេខាំកកេរដាច់ដែរ ! ចុះអញមិនមែនដែកឯណា វរៗវាមកកកេរអញចំថ្ពាល់អោយមានស្នាម អស់អួតទៅហើយ ! ណ្ហើយ សុំដាក់មេផាយសិនហើយ មាឌវាធំណាស់ ហើយវាជាប្រុសទៀត !"

ដោយសារតែគិតយ៉ាងនេះហើយ ទើបដានីដើរចេញទៅយ៉ាងស្ងួត ។

ពណ្ណរាយម្ទីម្នាដើររកកន្លែងថ្មីកប់ប្រដាប់លេងរបស់វា ។ លុះរួចរាល់សព្វគ្រប់ហើយ វាក៏រត់ទៅកាន់សាលាបាត់ទៅ ។

ឥឡូវនេះជាពេលចេញមកពីសាលាវិញហើយ ដានីខ្លាចពណ្ណ-រាយគុំលួចវៃតាមផ្លូវ នាងតូចក៏បបួលមិត្តនាងទាំងពីរនាក់ ដើរមកជាមួយ ។ ពេលមកដល់កណ្ដាលផ្លូវ ស្រាប់តែឮសូរគេឈ្លោះគ្នា ដានីនាំ



ហ្វូងរបស់នាងរត់យ៉ាងលឿនទៅចោមរោមមើល ឃើញកុមារពីរនាក់កំពុងតែទាត់ធាក់គ្នា ។ ម្នាក់គឺជាក្មេងកាចជាងគេនៅក្នុងភូមិនេះឈ្មោះអាម៉ាប់ ម្នាក់ទៀតគឺពណ្ណរាយ ។ អាម៉ាប់កាចណាស់ ហើយជាក្មេងក្អេងក្អាងបំផុត ប្រហែលវាឃើញពណ្ណរាយទើបនឹងមកថ្មីមិនព្រមអោនលំទោននឹងវាហើយ ទើបវាកាច់បំបាក់យ៉ាងនេះ ។ អ្នកឈរមើលមានចំនួន ៦ នាក់ រួមទាំងដានីផង ។ គូបដិបក្សទាំងពីរសុទ្ធតែជាកុមារដែលដានីមិនចូលចិត្ត បើអាម៉ាប់ចាញ់ក៏ដានីមិនព្រួយចិត្ត ព្រោះអាម៉ាប់ខូចណាស់ នរណាក៏ស្អប់ដែរ តែអាម៉ាប់វាមិនដែលមើលងាយឬធ្វើបាបដានីទេ ព្រោះអាម៉ាប់វាមានសក់កន្ទ្រើងៗហើយសរសៃរឹង ដូច្នេះវាតែងមកសុំផ្លែននោងសាញព្រៃដែលដុះកៀនរបងផ្ទះដានី យកទៅធ្វើថ្នាំកក់សក់របស់វា ឃើញថាវាចាត់ទុកនាងថាជាមនុស្សក្មេងធំម្នាក់ដែរ ឯពណ្ណរាយជេរនាងពេញៗមាត់ ហើយមើលងាយនាងណាស់ ល្មមតែអោយអាម៉ាប់វាយដូចនេះ រុញទំលាក់ភក់បាតបឹងអោយប្រកាច់ម្ដង ។

ក្មេងប្រុសទាំងពីរមានស្នៀតប្រយុទ្ធល្អណាស់ អាម៉ាប់ចាប់វាតទីឈ្នះរាប តែម្ដងនេះវាដូចជាមានការពិបាក ក្នុងការផ្ដួលរំលំពណ្ណរាយជាពន់ពេក ។

ដានីឈរមើលមិនសុខ ក៏និយាយទៅមិត្តៗវា ÷

- ក្មេងដែលដាល់គ្នាជាមួយអាម៉ាប់ មុខវាក្រហមណាស់ មាន់ប្រជល់បើមុខវាក្រហមដូច្នេះ គេចាប់អោយទឹកវា !

មិត្តដានីម្នាក់ ប្រហែលអាណិតពណ្ណរាយហើយ ទើបឆ្លើយទាំង

អាណិតថា ÷

- ហ៊ឺ !... មាឌអាម៉ាប់ធំណាស់ ! បើវៃគ្នាយូរបន្តិច បងមួយដែលមុខក្រហមនោះ ច្បាស់ជាហត់មុន ! ដានីហ្អា ! គេជល់មាន់ បើមុខវាក្រហមគេត្រូវឱ្យទឹក ចំណែកមនុស្សវៃគ្នាវិញគេត្រូវរកអាជ្ញាកណ្ដាលម្នាក់ សំរាប់ការពារនិងតាមដានការប្រយុទ្ធ ។ ដានីឯងជាកុមារីម្នាក់មានលក្ខណៈពិសេសជាងគេក្នុងរឿងនេះ បើតាមយោបល់ខ្ញុំឯងត្រូវតែប្រកាសខ្លួនធ្វើអាប៊ីត ដូចពូៗលេងបាល់នៅឯវត្តអីចឹងទៅណា៎ !

មិត្តដានីទះដៃភ្លាម ជាសញ្ញាថាគាំទ្រមតិនេះហើយ ព្រោះគេគ្រប់គ្នាចូលចិត្តយកដានីធ្វើតំណាងជាន់ខ្ពស់ណាស់ មិនថាលេងល្បែងឬទៅណាមកណាទេ ។ អាម៉ាប់វាធ្លាប់ទៅសុំននោងសាញដែលជាថ្នាំកក់សក់ពិសេសរបស់វានៅឯផ្ទះដានី ដូច្នេះវាច្រើនយកចិត្តទុកដាក់នឹងដានីដើម្បីស្រួលសុំថ្នាំកក់សក់ ។ មិត្តៗដានីក៏ស្ទុះទៅជួយចាប់គូប្រយុទ្ធទាំងពីរហើយនិយាយស្នើថា ÷

- អ្នកទាំងពីរកាច់ចំបាប់គ្នាអត់អាជ្ញកណ្ដាលយ៉ាងនេះ ធ្វើឱ្យអ្នកមើលពិបាកចូលមកចាប់ណាស់ ! ដូច្នេះគួរតែអោយដានីធ្វើអាជ្ញាកណ្ដាល ដើម្បីកុំអោយជ្រុលដៃជ្រុលជើងមានរបួសធ្ងន់ ។ កើតមកជាប្រុសត្រូវទាត់ធាក់គ្នាដូច្នេះហើយ ទើបដុះសេចក្ដីក្លាហានហ៊ានវាយខ្មាំងដែលវាហ៊ានមកយាយីស្រុកភូមិយើង.... ប៉ុន្តែការប្រយុទ្ធត្រូវមានម្នាក់ចាញ់ម្នាក់ឈ្នះ បើគ្មានអាជ្ញាកណ្ដាលទេ... អ្នកឈ្នះប្រាកដជាវាយអ្នកចាញ់ទ្រមខ្លួនបណ្ដាលអោយមានរបួសធ្ងន់ ។ ឯងទាំងពីរប្រយុទ្ធគ្នាគ្រាន់



តែអោយដឹងថានរណាខ្លាំង នរណាខ្សោយបានហើយ មិនបាច់ធ្វើអោយរបួសគ្រាំគ្រាម្នាក់ៗទេ !

អាម៉ាប់ព្រមឈប់ភ្លាម ព្រោះវាកំពុងហត់ដែរ... បានគេបង្កើតអាជ្ញាកណ្ដាល វាអាចនឹងសំរាកអោយបានបាត់ហត់បន្តិច រីឯពណ្ណរាយវាហាក់ដូចជាទីទើរបន្តិច ព្រោះអោយដានីធ្វើមេអាប៊ីតនាំអោយវាឱនក្បាលគោរពនាងមុនពេលប្រយុទ្ធគ្នា ដូច្នេះដានីមិនធំជាងវាទៀតឬ ? ពណ្ណរាយមិនចង់ធ្វើតាមមតិជុំវិញខ្លួនសោះ... ប៉ុន្តែកាលៈទេសៈនេះ ធ្វើអោយវាប្រកែកមិនរួច ក៏ព្រមអោយបង្កើតអាប៊ីតដូចគេបានលើកឡើងនៅខាងលើ ។ អាប៊ីតដានីសើចស្ងាញហើយក្អេងក្អាងថា ÷

"ឯងជាគូប្រយុទ្ធ .... រីឯអញជាអាប៊ីត គឺអញនេះហើយធំជាងគេ ! ទីបំផុតឯងអោនក្បាលគំនាប់អញមែន ! យី ! អាប៊ីតពូៗច្រើនតែនៅកណ្ដាល ហើយចាប់ដៃគូប្រយុទ្ធអោយរលាក់គ្នា ... អញធ្វើម៉េចអោយសម ?"

ដានីដើររលាក់សក់កំប៉ោយពីរ ដើរចូលកណ្ដាលគូប្រយុទ្ធហើយបង្កើតសំនួរខ្លួនឯងថា ÷ "តើមនុស្សធំជាងគេធ្វើអាជ្ញាកណ្ដាល តាំងឫកពាបែបណាទៅហ្ន៎ ? ... វរៗអញធ្វើមិនសម គេស្រែកថាដានី ក្មេងណាស់ ! នៅស្ទើរ នៅល្ងង់ ធ្វើអាប៊ីតមិនកើត ... អញខ្មាសគេរត់ចោលស្រុកហើយ .... យីហោដានីឆ្លាត.... យីហោដានីនៅក្មេងតែឫកពាចាស់ទុំច្បាស់ជាបះជើងមិនខាន !" ដោយខ្លាចដូច្នេះហើយ ទើបដានីខំរៀបឫកពាអស់ពីចិត្ត ....

ដានីដើរយ៉ាងអង់អាច ឈានជំហានមួយៗ ហើយឈប់ង៉ក់កណ្ដាលគូប្រយុទ្ធ ព្រមទាំងធ្វើទឹកមុខមាំ ពុំមានសើចឬញញឹមឡើយ ។

មិត្តដានីខ្សិបៗឮៗ ÷

- យី ! ដានីធ្វើអាប៊ីតសមណាស់វើយ !

- តូចតែខ្លួនទេតែឫកពាដូចមនុស្សចាស់ អញសុំកោតវាហើយ!

- ថ្ងៃក្រោយ អញសង្ស័យតែធ្វើមេទ័ពស្រីទេ បើវាពូកែខាងបញ្ជាគេយ៉ាងនេះ !

- តែបើតាមអញដឹង... វាចង់ធ្វើជាជាងកាត់សក់ ព្រោះវាចង់កាន់ក្បាលគេ ដើម្បីអោយគេអន់ជាងវា !

- ចេះតែនិយាយស្មាន ហើយដានីវាចង់ខ្ពស់យ៉ាងនេះ វាមិនមែនសុខចិត្តធ្វើជាងកាត់សក់អោយគេយកលុយទៅជូលវា អោយបំរើគេនោះទេ តាមស្មានវានឹងធ្វើប្រពន្ធកុង្សីផង ព្រោះឫកពាវាជាមនុស្សមានអំណាច បើប្ដីវាមានកូនទាហានមួយបាតាយ៉ុង...ឯងចាំមើលចុះ បើអញថាខុស !

អាម៉ាប់ចង់សើច រីឯពណ្ណរាយក៏នឹកចង់សើច នឹងវាចានាងៗដែលលាន់ឡើង តែសំលេងមិនដឹងមុខមួយណានិយាយទេ ព្រោះគេខ្សិបគ្នា .... តែខ្សិបកណ្ដាលវាល សំលេងលាន់ឡើងឮច្បាស់ថែស ។

ដានីនៅតែធ្វើមុខមាំ ហើយលើកដៃឱ្យសញ្ញាថា ប្រុងប្រៀបប្រយុទ្ធ ។ កុមារាម្នាក់បានស្ទុះមកអោយយោបល់ ÷

- នែវើយ! អញធ្លាប់ទៅមើលគេវ៉ៃបុកនៅទីក្រុង គេតែងចែកជាបង្គោលខៀវ... បង្គោលក្រហម ហើយមានថ្នាយគ្រូទៀតផង ! ពួកឯងពីរនាក់នេះ មួយណាបង្គោលក្រហម មួយណាបង្គោលខៀវ ?



ពណ្ណរាយនិងអាម៉ាប់ អត់ពាក់អាវដូចគ្នា ព្រោះវាប្រតាយគ្នាដាច់ឡេវអាវ ហើយក៏ដោះក្រវាត់ចោលទៅដីគ្មានសល់អ្វីទេ នៅសល់តែខោស្ទាប់ភ្លៅដូចគ្នា តែពណ៌ផ្សេងគ្នា ។ ដានីប្រកាសថា ÷

- អ្នកស្លៀកខោខៀវជាបង្គោលខៀវ ឈ្មោះពណ្ណរាយ អាយុ ១២ ឆ្នាំ ទំងន់តាមស្មាន ២៥ គីឡូក្រាម ប្អូនប្រុសពណ្ណរាយទើបនឹងមកដល់ស្រុកយើង ដោយចិត្តជាកូនប្រុសជើងហាក់លោត គេចង់ស្គាល់ជើងខ្លាំង ដើម្បីល្បងថ្វីដៃជាមួយប្អូនម៉ាប់ ដែលជាជើងឯកប្រចាំភូមិយើងនេះ ! បង្គោលក្រហមគឺជាអ្នកស្លៀកខោក្រហម ដែលមានឈ្មោះថាម៉ាប់ ទំងន់ប្រហែល ២៧ គីឡូក្រាម អាយុ ១៣ ឆ្នាំជាអ្នកស្រុកយើងនេះ ! ហ៎ក ! ទាំងពីរនាក់សូមប្រុងប្រៀប !

គូប្រយុទ្ធថ្វាយបង្គំគ្រូបន្តិច ហើយងាកមកគោរពអាប៊ីត ដើម្បីចាប់ផ្ដើមប្រយុទ្ធ ។ អ្នកមើលកេះគ្នាពិចារណា ÷

- ចុះដានី វាអាយុប៉ុន្មានហៅគេប្អូនៗ ?

- យី ! វាជាអាប៊ីតណា ! ពេលនេះវាជាអ្នកធំលើគូប្រយុទ្ធ វាត្រូវតាំងខ្លួនធ្វើធំជាងដូច្នេះហើយ ! មនុស្សដូចដានី ទេវតាបង្កើតមកសំរាប់ធ្វើអ្នកធំអញ្ចឹង! មើលចុះវាលេងស្ដេចចង់ ទារធ្វើតែស្ដេចទេ លុះគេវាយបុកគ្នាទារធ្វើអាប៊ីតទៀត វាធ្វើសមផងហើយសំដីបែបថ្លោសៗទៀត !

ពណ្ណរាយគោរពអាប៊ីតខ្ទីខ្ទាបំផុត ក្បាលដែលអោននោះស្ទើរតែមិនកំរើក ។ ដានីបែរមុខចេញហើយរលាស់សំដីថា ÷

- ការគោរពបើកឆាកប្រយុទ្ធសំខាន់ណាស់ បើគោរពអាប៊ីតដូចជាខ្ជិលយ៉ាងនេះ... អាប៊ីតគ្មានកំលាំងតាមដានការប្រយុទ្ធទេ... សូមគោរពជាថ្មីម្តងទៀត !

អាម៉ាប់អោនក្បាលចុះស្ទើរដល់ដី ÷

- សូមគោរពលោកអាប៊ីត !

ពណ្ណរាយមិនអាចតវ៉ាបានក៏អោនក្បាលទាំងប្រទេចក្នុងពោះ ÷ "មីតូចច្រម៉ក់នេះ សំបើមមែន ! ថ្ងៃនេះស្ទើរុញវា បានជាអញអោនក្បាលគោរពវាត្រង់ជើងល្មម្ល៉េះ ? ស៊ិយមែន ! បើតប់គ្នាចាញ់គេ អញមិនយកមុខទៅលាក់ទុកនៅក្រហែងណាទេ !"

ដានីញញឹមខ្ទឹប កាលបើពណ្ណរាយអោនក្បាលគោរពយ៉ាងត្រឹមត្រូវ ។

"ទៅណាវា ! យីអ៊ុនអញនៅតែខ្ពស់ត្រូវតែមកឈរអោនក្បាលគោរពអញអីចឹង ! ហាស១...ថ្ងៃក្រោយបើអញបានពាក់ផ្កាយ ៣ សូមអោយអាគាត់នេះពាក់ផ្កាយមួយ មកឈរគោរពអញត្រុន១ទៀត !"

ដានីឈរយ៉ាងសឿង ចាប់ដៃអ្នកទាំងពីរឡើងលើ ដោយស្រែកថា ÷

- ហ៉ក ! ចូលប្រយុទ្ធ !

គូប្រយុទ្ធក៏ចូលប្រឡូកគ្នារក់រឺដូចជ្រូកពុល ដូចដឹងស្រាប់ហើយ



អាយុ ១២ និង ១៣ ឆ្នាំ កំពុងស្ទាវខ្លាំងណាស់ ហើយគ្មានក្បួនច្បាប់វៃគ្នា ត្រឹមត្រូវអ្វីទេ .... ប្រទាញទៅប្រទាញមកដូចស្គរកៅស៊ូ ស្អិតតតាត់គ្មានរបេះពីគ្នាកើតឡើយ .....។

ដានីខំតាមដានការប្រយុទ្ធដោយរត់តាមមើលប្រកិត១... ស្រាប់តែគ្រាំង ! អាម៉ាប់និងពណ្ណរាយប្រតាយគ្នា ធ្លាក់ប្រ្លូងទៅក្នុងភក់បាតបឹង ដែលរីងនៅខែប្រាំងកប់បាត់ស្រមោល .... វាទាំងពីរឈប់ប្រតាយគ្នាហើយ ប្រឹងងើបឡើងដើម្បីកុំឱ្យភក់ស្រូប ។ អាប៊ីតក៏ប្រកាសភាពអាសន្ន សុំអោយអ្នកមើលជួយទាញជើងឯកចំបាប់ទាំងពីរ ដែលមានរង្វាន់កិត្តិយសជាភក់ជាប់លំអ ។

- សូមអ្នកមើលជួយផង ! ជើងឯករបស់យើង យល់ថាភូមិយើងថវិកាខ្សត់ខ្សោយ នាំគ្នាទទួលរង្វាន់ពីភក់បាតបឹងហើយ !

ក្រុមអ្នកមើលហោ៊ក្រេវ១ ....

- ជយោ១ ! ឈ្នះដូចគ្នា ! ព្រោះបានរង្វាន់ភក់គ្របក្បាលដូចគ្នា ! អញកោតណាស់ ទទេ១នាំគ្នាទៅទូលភក់ ! ខ្វះអីរង្វាន់ផ្សេងពីនេះម៉េចក៏មិនទៅទទួល បែរជានាំគ្នាទៅស៊ីភក់ផង ផឹកភក់ផង ទូលភក់ផងហើយប៉ាតភក់ជំនួសម្សៅទៀតផង ! ហ៊ឺ ! អាឯងពីរនាក់នេះ យប់នេះដេកក្រោមផ្ទះទៅ ចាក់ទឹកមួយពាងក៏មិនជ្រះដែរ ភក់ល្បាប់លាយសំរាមបែកទឹកពពុះព្រិច១យ៉ាងនេះ ស្អុយអាក្រក់ណាស់ កុម្ម៉ង់ទឹកអប់ពីទីក្រុងមកចាក់ច្រួចដប់ម្តែដបអីទៅ ទើបបាត់ក្លិនស្អុយ !

ដានីខំតាំងឫកពាជាមនុស្សចាស់នោះ ក៏មិនអាចទប់ខ្លួនមិនឱ្យ

សើចបានដែរ ... នាងតូចសើចយ៉ាងសប្បាយជាមួយពួកឈរមើល ពេលជាមួយគ្នានោះ ស្រាប់តែក្របីឡើងកដាច់ខ្សែមកទីនេះ ។ ក្របីឃើញកុមារប្រលាក់ភក់ទាំងពីរ ស្រមេកស្រម៉កហើយដូចជាចំលែក វាក៏ស្ទុះទៅរក...ពួកក្រុមកុមារទាំងអស់ភ័យណាស់ នាំគ្នាស្រែកប្រាប់ពណ្ណរាយនិងអាម៉ាប់ថា ÷

- រត់ ! រត់វ៉ើយអាពីរនាក់ ! ក្របីវិធអស់ធ្មេញឥឡូវហើយ !

ឱ ! សែនអនិច្ចា ភក់ល្បាប់ជាប់នឹងដងខ្លួនកុមារទាំងពីរធ្ងន់ណាស់ រូតរឹតស្បែកវាតឹងស្អិត រកតែបោះជំហានដើរមិនចង់រួចផង តើវាមានកំលាំងឯណាអាចរត់បាន ? អាម៉ាប់ភ័យណាស់ វាមិនខ្លាចខ្មាសនរណាទេ វាយំងោ៉ង ស្រែករោទិ៍ដូចជ្រូកត្រូវទឹកក្ដៅ ស្រែកហៅអ្នកជិតខាងដែលនាំគ្នារត់ឡើងដើមឈើអស់ទាំងនោះ ទាំងភក់ស្រក់ចូលមាត់ ។

- អាខ្មៅ ! អាព្រីង ! ស្រាតខោហ្លែងចងមែកឈើគ្រវីចុះមកក្រោមភ្លាមមក ! ក្របីវិធអញបាក់ជើងខានដើរឥឡូវហើយ ! ហ៊ឺ... អាចោលម្រ៉ាយ នាំគ្នារត់ចោលអញអស់ ប្រយ័ត្នអញរួចខ្លួន អញវៃទំលាក់ភក់វ៉ើយ !

ដានីឡើងដើមក្រសាំងមិនរួចទេ នាងតូចរត់ស្រវាឡើងដើមត្របែកដែលទាប១ ដើម្បីគេចពីក្របី ។ នាងឮច្បាស់ថាអាម៉ាប់ស្រែករកគេជួយ តែនាងចង់ឮមាត់ពណ្ណរាយស្រែកម្នាក់ទៀត តើអ្នកក្លាហាននេះវាមានភ័យស្លន់យំរោទិ៍ដូចអាម៉ាប់ដែរឬទេ ?



ក្របីធុំក្លិនភក់វាដើរចូលកាន់តែជិតអាម៉ាប់ និងពណ្ណរាយកៀកឡើង១ ។ អាម៉ាប់យំព្រិច១ ឮសូរដូចស្គរទូង រីឯពណ្ណរាយវាក៏ភ័យណាស់ដែរ ប៉ុន្តែវាគ្មានពួកម៉ាកសំរាប់ស្រែកអោយជួយឡើយ ... ដូច្នេះវាក៏នៅស្ងៀម បន់ដូនបន់តាតែក្នុងពោះម្នាក់ឯងទៅ ។

ដានីឃើញក្របីកាន់តែកៀកវាទាំងពីរមែនទែនហើយ នាងតូចទ្រាំលែងបានក៏ស្រែកប្រាប់អាព្រីង ។

- ស្រាតខោក្រហមចងទំលាក់មកខ្ញុំព្រីង ! ខ្ញុំកាច់មែកត្រ-បែកចងខោយោគអោយក្របីវារត់ !

អាព្រីងស្រាតខោវា បោះទំលាក់អោយទើរលើដើមត្របែក ។ ដានីឆ្កឹះយកខោមក ហើយកាច់មែកត្របែកមួយចងនៅខាងចុង ព្រយិតដើមត្របែកគ្រវីផង ស្រែកផង ។

- យី១ ! ...... យោ១ ! ......

អាខ្មៅ អាព្រីង អាគ្រាក់ ពីរបីនាក់ទៀត សូរពីដើមអំពិលមកដើមត្របែក រួចស្រាតខោខ្វាច់១ ចងនឹងមែកត្របែករត់ទៅបន្លាចក្របីស្រែកបង្អើលលាន់រំពង ...... ក្មេងដទៃទៀត វាលែងខ្មាសអៀននរណាហើយ ឃើញពួកមុន១បង្អើលក្របីដូចជាសប្បាយ វាក៏នាំគ្នារកមែកឈើចងគ្រវីដេញក្របីដូចព្យុះមួយរយមេ .....

អាម៉ាប់ឈប់យំភ្លាម ហើយហ៊ោក្រេវ១ដោយសប្បាយ ព្រោះអាដែងដេញក្របីអស់នោះ រត់ទាំងស្រាតមួយកំណាត់ខ្លួន គ្មានគិតអីសោះ ។ រីឯពណ្ណរាយវិញ វាជាកុមារទីក្រុង ឃើញកុមារដេញក្របីទាំង

នោះស្រាតគ្មានញញើតធម្មជាតិយ៉ាងនេះ វាខ្មាសជំនួសណាស់ វាមិនបានដឹងថា អាដែងដេញក្របីទាំងនេះ ពេលទៅប្លុងក្នុងទឹកបឹងរាល់ថ្ងៃតឺនុយស្លៀកមេឃទេ ។

ក្របីដាច់ខ្សែឬស្លូវយ៉ូសយ៉ាស និងខោចំរុះពណ៌គ្រវីគ្រវាត់ជុំវិញវា វាភ័យដែរក៏រត់ត្រុយ លែងទៅក្បែរអាម៉ាប់និងពណ្ណរាយ ។ ក្របីទៅបាត់ដានីអរណាស់ លោតពីមែកត្របែកភ្លេចគិតក៏គ្រិចជើង ងើបលែងរួច ....

- អូយ ! .... អូយជួយខ្ញុំផង ! ធ្លាក់ពីដើមត្របែក ក្រោកដើរអត់រួចទេ !

កុមារអត់ខោទាំងអស់ ស្ទុះមករកមើលដានី នាងតូចបិទភ្នែកស្រែកយ៉ៃ ÷

- ខ្ញុំមិនមែនក្របីទេ ... ស្លៀកខោសិនទៅ !

ពួកស្រាតខោទាំងនោះ ក៏ទាញខោពីមែកត្របែក មកស្លៀកភ្លែត១មិនបាច់ភ័យនឹងរកកន្លែងសមគួរ ស្រាតក៏លឿន ស្លៀកក៏រហ័សណាស់ដែរ ។ អាព្រីងអោនសួរដានីថា ÷

- បងស្តេច ! (ដានីត្រូវគេហៅថាបងស្តេច ព្រោះរាល់១យប់លេងស្តេចចង់ ពួកក្មេង១អោយដានីធ្វើស្តេចរហូត) ដើរទៅផ្ទះរួចទេ ? បើមិនរួចពួកយើងជួយអៀវ !

អាខ្មៅស្លៀកខោរួចហើយដែរ វាមកក្បែរអាព្រីងលត់ជង្គង់ចុះទាញជើងដានីសាកលមើល ។



- បងស្តេច ! បើចុកស្រែកថាចុកណា៎ !

និយាយរួច វាសាកទាញជើងនាង តែដានីស្រែកយ៉ៃ ÷

- ឈឺណាស់ !

អាម៉ាប់ស្រែកទាំងភក់ស្រម៉ុកថា ÷

- ជើងបងស្តេចថ្លោះហើយដើរមិនរួចទេ ពួកឯងអៀវទៅផ្ទះទៅ !

អាព្រីងអេះក្បាល ÷

- មើលអាណាផ្លូវទៅជាមួយបងស្តេចខ្លះ លើកដៃមកមើល ? អញនៅចុងភូមិខាងជើងប៉ែកខាងស្តាំឯណោះ ! អាណាផ្លូវទៅខាងកើតល្មមដឹងខ្លួនហើយ !

អាខ្មៅចង្អុលទៅពណ្ណរាយ ÷

- មានតែអាមួយនោះ ផ្ទះវានៅក្បែរបងស្តេច អោយវាអៀវទៅ !

អាព្រីងមើលទៅគ្នាវាម្នាក់ដែលលើកដៃសុំអៀវដានី ÷

- អូហ៎ ! អាឆ្លូញដើរផ្លូវនោះដែរ អោយវាជួយអៀវបានពីរនាក់នឹងអាមួយថ្មីនេះទៅ ណ៎ ! អាល្បងពណ្ណរាយអីតេនេះមកតាមអញទៅហក់ទឹកបឹងត្រង់កន្លែងជ្រៅឱ្យជ្រះភក់ចេញ ហើយអៀវបងស្តេចយកទៅដាក់ផ្ទះផង !

វាមិនទាន់ថាម៉េចផង អាព្រីងនិងអាខ្មៅអូសដៃវាឱ្យដើរតាមក្រោយអាម៉ាប់ទៅរកទឹកបឹងកន្លែងជ្រៅ ដើម្បីលាងសំអាតខ្លួន ។

ថ្ងៃកាន់តែខ្ពស់ហើយ ដើម្បីឱ្យឆាប់ដល់ផ្ទះ អាខ្មៅនិងអាព្រឹង ចុះទៅជួយលាងភក់វាទាំងពីរ ។

អាព្រឹងចុះផងនិយាយផង ។

- ថ្ងៃចំកណ្ដាលក្បាលហើយវើយ ! អញឃ្លានបាយណាស់ ! អាម៉ាប់ហ្អែងឃ្លានបាយដែរហ្អាំ ?

- អញឃ្លានជាងឯងផង វៃគ្នារូចឡើងហេវ ភក់ចូលមាត់អញប្រែៗ តែដូចជាមានជាតិ !

អាខ្មៅដែលកំពុងជួយដុសក្អែលភក់អោយពណ្ណរាយ វាអោយយោបល់ថា ÷

- អញក៏ឃ្លានណាស់ដែរ ហ្អែងទាំងបីចាំអញមួយភ្លែត អញទៅកាច់ឈូកយកចែកគ្នាស៊ី !

អាម៉ាប់វាតវ៉ាថា ÷

- ហ្អែងទុកអាពណ្ណរាយ អោយវាដុសលាងម្នាក់វាទៅ មកជួយដុសអញអោយជ្រះ អញស្គាល់កន្លែងឈូកផ្លែច្រើន ទៅមួយភ្លែតបានមួយថ្នក់ធំ យកទៅចែកពួកយើងនៅលើគោកស៊ីផង !

- អាពណ្ណរាយចាំពួកយើងនៅកន្លែងនេះហើយ អញទៅកាច់ឈូកយកមកចែកគ្នាស៊ីកុំអោយឃ្លានបាយពេក ! វរៗដើរមិនរួច ហ្អែងកុំទៅណា ចាំស្ដាយឈូកយកទៅចែកពួកខាងលើស៊ីផង !

ក្រុមអាម៉ាប់ទាំងបីនាក់ងើបចេញពីទឹកបឹង ដើរទៅរកកន្លែងដាំឈូក ។ អាព្រឹងមើលនាយមើលអាយ ÷



- ឈូកនេះតាឃ្លោកព្រោះគ្រាប់ដាំ ទុកអោយទុំយកទៅលក់ អញទៅនិយាយលេងជាមួយគាត់ អាម៉ាប់និងអាខ្មៅចូលលុកកាច់យកទៅអោយពណ្ណរាយ ជួយយកអាណាឡើងមេ្យា អោយវាយកទៅលើផង ចំណែកអញបើតាឃ្លោកគាត់ហៅស៊ីបាយ អញស៊ីសិនហើយ មិនបាច់ចាំអញក៏បានដែរ តែកុំភ្លេចយកទៅចែកគ្នាយើងនៅខាងលើ វាបាក់ពោះគ្រប់គ្នាហើយ !

អាម៉ាប់ និងអាខ្មៅឆ្លើយអឺៗ ហើយសសៀរៗទៅរកចំការឈូកក្នុងបឹង ។

អាព្រឹងទៅដល់រោងតាឃ្លោក ឃើញគាត់កំពុងតែកូរបាយឆ្នាំងលេខ ១០ ដាំទុកអោយពួកគ្នីគ្នាគាត់ដែលមកជួយរើសឈូកទុំ ។ អាព្រឹងក៏និយាយយកគួរសមថា ÷

- តា ! ខ្ញុំឃើញពូៗ បួនប្រាំនាក់គាត់ទៅចុះទឹកបឹង គាត់ថាក្ដៅណាស់មិនចង់ងើបពីទឹកទេ បើខ្ញុំដើរមកនេះឃើញតាជួយប្រាប់ផងថាគាត់សំរាកក្រោមដើមរាំង អោយខ្ញុំសុំបាយតាមួយកញ្ជើរ យកទៅជូនគាត់ពិសា !

តាឃ្លោកបែរមកមើលអាព្រឹង រួចនិយាយ ÷

- ចុះអាណាខ្លះដែលខ្ជិលដើរមកស៊ីបាយហ្នឹង ហ្អាសអាព្រឹង ?

- ពូកែម ! ពូកុប ពូសាញ ពូស្មោញអីហ្នឹងណាំ ! ម៉េចតាឆ្អិនបាយឬនៅ ?

- អញកំពុងជ្រោយ ! ចុះអាព្រឹងឯងមកពីណាបានជាជួបវា?

- បាទ ! តាខ្ញុំចុះពីរៀនទៅដោះក្របីអោយទឹក ទើបជួបពួកគាត់ លឿនឡើងតាពួកគាត់រអ៊ូថា បាយក្រឆ្អិនពេកគាត់រត់ទៅផ្ទះអស់ឥឡូវហើយ !

- អើ ! មើលអាព្រីង ហ្អែងជួយអញផង ! យី ! ចុះស្អីឮព្រោកកន្លែងបឹងឈូក អាព្រីង ?

- ប្រហែលពួកពូៗ គាត់ឃ្លានពេកនាំគ្នាចុះដកក្រឡឹឈូកពិសាហើយ !

តាឃ្លោកឈប់សង្ស័យ ហើយដួសបាយដាក់ល្អី ថែមត្រីអាំងធ្វើម្ហូបអោយអាព្រីងទូលទៅ ។ អាព្រីងធ្វើជាធ្ងន់ដើរប្រហែល ១០ ម៉ែត្រលុះតាឃ្លោកមើលលែងឃើញ វាផាយយកតែមែនទែន កំពុងតែរត់លឿនស្រាប់តែប្រទះនឹងក្រុមពូៗកំពុងនាំគ្នាឡើងពីទឹកឈូក ។ អាព្រីងភ័យណាស់ .... ចុះអាម៉ាប់និងអាខ្មៅវាកាច់ឈូកបានដែរ ? អាព្រីងម្ទីម្ទាយកល្អីបាយទៅលាក់ក្នុងគុម្ពោតព្រៃ ហើយសំងំពួនមិនឱ្យពូៗទាំងនោះឃើញទេ វាឃើញអ្នកដើរមកមានពូកែម ពូកុប ពូសាញ ពូស្មាញ ដូចវាទាយមែន ។ អាព្រីងវាសប្បាយចិត្តណាស់ អើតក្បាលចេញពីទីពួនទៅឈរស្កាក់មុខពូៗទាំងនោះ ហើយភូតថា ÷

- តាឃ្លោកគាត់ផ្តាំតាមខ្ញុំមកថា បាយមិនទាន់ឆ្អិនទេ សូមឱ្យពូៗបេះឈូកខ្ចីពិសាសិនទៅ !

ក្រុមបេះឈូកពិគ្រោះគ្នាហើយ ចុះបេះឈូកមួយចំអែតបំបាត់ការស្រេកឃ្លាន ។ អាព្រីងបានឱកាស ស្ទុះរឹងទូលល្អីបាយរត់លឿនទៅ



កាន់កន្លែងគូកនវា ពេលនោះអាម៉ាប់និងអាខ្មៅ ក៏វេចអាវខ្ចប់ដើររត់ៗជាមួយពណ្ណរាយមកជួបនឹងអាព្រីងនៅកន្លែងណាត់ជួប អាម៉ាប់និយាយថា ÷

- អញលួចឈូកម្តងនេះស្រួលណាស់ ព្រោះពូៗកំពុងតែលួចកាច់ស៊ីដែរ គ្មាននរណាគេដឹងទេ ! យី ! ចុះអាព្រីងទូលអីហ្នឹង ?

- អញទូលបាយមួយល្អីនេះចែកគ្នាស៊ី !

- ចុះហ្អែងបានពីណាមក ? លួចតាឃ្លោកមែនទេ ?

- អត់លួចទេ ! គាត់អោយអញទូលអោយពូៗបេះឈូក ! ចុះបើពួកយើងដេញក្របីហាត់យ៉ាងនេះ ឃ្លានបាយចង់ងាប់ដើរទៅផ្ទះម៉េចរួច ! ឃ្លានចង់ងាប់ អញគិតថានាំគ្នាស៊ីបាយឆ្អែតមិនបាច់ទៅផ្ទះ នាំគ្នាទៅរៀនវិញ !

- អើ ! ដូចជាម្យ៉ាងដែរ ពួកយើងប្រញាប់ទៅកាន់កន្លែងដានីសំរាកជាមួយគ្នីគ្នាវាច្រើននាក់ទៀត !

- ទុកឈូកស៊ីក្រោយរឿយ នាំគ្នាស៊ីបាយសិន !

- អញឃ្លានណាស់ ចុះអាម៉ាប់វាទៅទិញបាយពីណាមក ?

(សំដីកុមារម្នាក់)

- អញមិនបាច់ទិញទេអាព្រីងវាជាអ្នករកបាយឱ្យពួកយើងស៊ី !

- អញប្រាប់អោយដឹងទៅ បាយនេះលួចគេទេ អាណាមិនចេះធ្វើចោរកុំស៊ីរឿយ បើស៊ីហើយខ្ជាក់មកវិញភ្លាម អញអត់បូកសរុបចូលគ្នាទេ !

ពណ្ណរាយជាក្មេងទីក្រុង វាធ្លាប់ទទួលការប្រៀនប្រដៅឱ្យមានឫកពាថ្លៃថ្នូរ និងហាមមិនអោយលួចទ្រព្យរបស់គេ ពេលនេះវាឃ្លានណាស់ ព្រោះវាវៃគ្នាមួយទឹកពោះបាក់ជាប់ឆ្អឹងខ្នង វាកាយបាយបញ្ចូលមាត់បានបួនប្រាំម៉ាត់ទៅហើយ ឮពាក្យអាម៉ាប់និយាយ វាដូចជាញាក់បាយតទៅទៀតលែងរួច ។ វាដៀងភ្នែកមើលគេឯង ស្រាប់តែឃើញដានីមើលមករបៀបចុងភ្នែក វាដូចជាខឹងបន្តិចដែរ ក៏អោនមុខបន្តិចទៅវិញ ។ ដានីវៃផ្លែភ្លាមថា ÷

- ម៉ាប់អើយ ខ្ញុំមិនធ្លាប់អត់បាយដល់ថ្មើរនេះទេ ខ្ញុំឃ្លានណាស់ ជួយរិតខ្នងអោយចេញបាយមកវិញភ្លាម ! ខ្ញុំខ្វាក់មកវិញមិនចេញទេ !

ទាំងអស់គ្នាសើចគិល ។

ពួកក្មេងៗទាំងនេះលែងគិតអ្វីច្រើន ព្រោះវាឃ្លានខ្លាំង គ្រាន់តែបានបាយចូលមាត់វាទំពារយ៉ាងឆ្ងាញ់ គ្មានគិតគូរអ្វីទាំងអស់ រួមជាមួយដានីមួយដែរ បាយមួយល្អីរលីងធែង ពួកវានាំគ្នាជូតដៃជូតមាត់ អាព្រីងយកបាយដែលជាប់នឹងល្អីរោយលើសក់ ។

- អាព្រីង ! យកល្អីទៅអោយតាឃ្លោកវិញ !

- អញមិនទៅទេ វីវរជួបពូៗ ចាំល្ងាចអញយកទៅប្លុងអោយគាត់វិញ ឥឡូវលាក់សិនទៅ !

អាម៉ាប់រកកន្លែងលាក់ល្អីស្រាប់តែ ÷

- ចោរម្រាយហើយ ! ស្អីសើមៗខោអញ ? ជួយមើលអញផង អាខ្មៅ !



អាខ្មៅប្រុងជួយមើលអាម៉ាប់ស្រាប់តែវាដូចជាមិនស្រួលដែរ ÷

- អញដូចជាមិនស្រួលដែរ ....

វាទាំងពីរយកដៃទៅស្ទាបហើយច្រលោតតោត ។

- ជួយអញផង ! ឈ្លើងចូលគូថឈាមច្រើនណាស់ !

អាព្រីងរអើលៗខ្លួនស្ទាបមើលដែរ តែមិនអីក៏ក្រលេកមើលទៅពណ្ណរាយហើយយកដៃខ្ទប់ភ្នែក ÷

- អូយ ! អាម៉ាប់ ! អាខ្មៅ ! ពណ្ណរាយ វាស៊ីបាយឆ្អែតនោមសុទ្ធតែឈាម ឈ្លើងចូលពេញពោះហើយ សង្ស័យតែកាត់ពោះវៀនដាច់អស់ ។

ពណ្ណរាយងាកមើលក្រោមគូថវាឃើញសុទ្ធតែឈាម ប្រាកដជាឈ្លើងទាមវាដោយមិនដឹងខ្លួនសោះ ។ អាម៉ាប់ អាព្រីង ស្រាតខោខ្វាក់ហើយហៅគ្នីគ្នាអោយជួយចាប់ឈ្លើង ។

- ជួយអញផង ! អាណាចាប់បានអញអៀវទៅរៀន ១០ ថ្ងៃ!

ពួកក្មេងៗដែលឈ្លើងអត់ទាម ស្ទុះទៅរកមើលអាម៉ាប់ ហើយបញ្ជាអោយអាម៉ាប់ចំតិតគូថ ។ អាម៉ាប់ចំតិតភ្លាមឈ្លើងចូលអស់ពាក់កណ្ដាលហើយ ក្មេងៗក្រញ៉ែងខ្លួនស្រែកយ៉ៃ ÷

- បេះមិនចេញទេវ៉ើយ ! ក្បាលវាចូលទៅពោះហ្វៀងហើយ !

អាម៉ាប់ស្រែករោទិ៍ជាថ្មី ។

- អញរមាស់ណាស់ ជួយអញផង ! អាណាជួយអញបានពេលនេះ អញសុខចិត្តហៅបងៗ ឬឪ និងម៉ែ !

ចប់សំលេងអាម៉ាប់ អាខ្មៅវាទូញ ÷

- មកពីអញខំទៅរកកាច់ឈូកអោយវាស៊ី បានជាឈ្លើងចូលឥឡូវអាណាជួយអញបាន អញសុខចិត្តធ្វើខ្ញុំវាមួយឆ្នាំ ប្រើអញអោយធ្វើអីក៏ធ្វើដែរ !

អាព្រឹងមើលទៅពណ្ណរាយ ÷

- ចុះអាពណ្ណរាយ ! ហ្អែងវាយ៉ាងម៉េចដែរ ?

ពណ្ណរាយមិនទាន់ស្រាតខោមើលសោះ ព្រោះវាចេះតែអៀនរកស្រាតមិនរួច ។

- ចុះហ្អែងមិនស្រាតខោអាពណ្ណរាយ ! ឈាមប្រលាក់ខោហ្អែងច្រើនណាស់ អាពីរនាក់នេះឈ្លើងចូលតែពាក់កណ្តាលទេ ចំណែកហ្អែងត្រាំទឹកយូរជាងគេ ប្រហែលជាឈ្លើងពីរបី ចូលទៅក្នុងគូថបន្តគ្នាហើយ !

ឮដូច្នោះពណ្ណរាយដូចជាភ័យដែរ តែវាស្រៀវខ្លួនណាស់ ភ្នែកជាច្រើនគូសំលឹងមកវា ជាពិសេសដានីតែម្តង វាខាំមាត់និយាយ ÷

- ស្រីៗបែរមុខចេញទៅ ! អញស្រាតខោ !

ក្មេងប្រុសៗសើចគិល ÷

- យី ! មើលអាពណ្ណរាយវានិយាយ អញដើរស្រាតពីបឹងរហូតដល់ចុងភូមិ គ្មាននរណាយកភ្នែកមើលផង ហ្អែងខ្មាសនឹងស្រីៗ តូចប៉ុនមេដៃអស់ហ្នឹង ! ងាប់ហ្អែងទេ ! មិនងាប់ស្រីៗអស់ហ្នឹងទេ !

- អញខ្មាសណាស់ ! អោយគេបែរមុខចេញទៅអាព្រឹង អញ



សូមអង្វរ !

អាព្រឹងស្រែកដោយភ្ញាក់ ÷

- អូហ៍ ! អញនឹកឃើញហើយ លើកមុនតាឃ្លោកឈ្លើងចូលគូថម្តង បានដានីយកអោយបាន ! នែ៎ ! ស្រីៗក្រៅពីដានីចេញមួយ ទៅណាទៅណីសិនទៅ ! ប៉ុន្តែកុំលួចមើលណា៎ !

អាព្រឹងដើរទៅពិនិត្យអ្នករបួសហើយរអ៊ូៗថា ÷

- យកថ្នាំជក់មកដាក់ បែបជ្រុះយ៉ាង !

ដានីគ្រវីក្បាល ÷

- មិនជ្រុះទេ ! ព្រោះក្បាលវានៅក្នុង កាលតាឃ្លោកឈ្លើងទាមខ្ញុំយកដើរីតវាញុកថ្នាំជក់តាមប្រលោះរីត វាពុលចេញមកវិញ !

- អើ ! បើដូច្នេះ ដានីឯងសាកលមើល ចុះពណ្ណរាយម៉េចមិនស្រាតខោ ឬក៏វាចង់ងាប់ ខ្មាសវាធំជាងងាប់ឬ ?

ទ្រាំមិនបានអាព្រឹងស្ទុះទៅទាញខោពណ្ណរាយ ហើយអុកពណ្ណ-រាយអោយហើបគូថឡើង ឈ្លើងទាមចូលក្នុងអស់សល់តែកន្ទុយបន្តិចបង្ហូរឈាមជាច្រើនចេញមកក្រៅ ។

- ចោលម្រាយហើយ ពណ្ណរាយជ្រៅជាងគេ ដានីមកមើលវាមុនគេ !

ដានីដើរចូលមក (អញធ្វើបាបអាគាត់នេះសិន) ។

- អាម៉ាប់ អាខ្មៅ ប្រាប់ថាបើនរណាជួយសុខចិត្តធ្វើអីៗ ចុះម្នាក់នេះយ៉ាងម៉េចដែរ ?

ពណ្ណរាយតូចចិត្តណាស់ មិនគួរកម្មក្រាស់មកជំពាក់គុណនារីតូចម្នាក់ ដែលវាសែនស្អប់យ៉ាងនេះទេ (មីល្អិតនេះ វាអីក៏យីអ៊ុនឡើងម្ល៉េះ ព្រឹកមិញអញជជែកចាញ់វា ឥឡូវត្រូវពឹងពាក់វាទៀតធ្វើម៉េចទៅ ?)

អាមាប់ស្រែកខ្លាំងៗថា ÷

- បើវាមិនទាន់សំរេចចិត្តទេ អោយដានីយកអញមុន អោយអញធ្វើអីក៏ធ្វើដែរ !

អាព្រីងស្រែកឡើង ÷

- អញដឹងណាស់ អាណាខ្លាំង អាណាមិនខ្លាំង ហ្អែងលិចតែមួយកំណាត់ខ្លួនទេ រីឯពណ្ណរាយវាជិតអស់ហើយ បើមិនជួយវាក្រែងហួសពេល នែ៎ អាព្រាយ ! (អាព្រីងហៅពណ្ណរាយអាព្រាយ) កុំញិមញ្ញមពេក អោយស្អីដានីបើវាជួយឯង ?

- ចុះអញធ្វើម៉េចនឹងដឹងថាគេចង់បានអីៗ ?

- បើដូច្នេះគេចង់បានអីហ្អែងអោយគេមែនទេ ?

- អីៗ ....

ដានីដើរមកជិតប្រាប់ទៅអាព្រីង ÷

- ថាខ្ញុំចង់អោយគាត់នេះអៀវខ្ញុំទៅរៀន អោយបានមួយខែទាំងព្រឹកទាំងល្ងាច ហើយហៅខ្ញុំថាមីងៗ !

- ហៅម៉ែតែម្តងទៅសោះនឹងវែងពេកម៉េចអាព្រាយឮទេហ្ន ?

ពណ្ណរាយហ៊ឹងត្រចៀកចង់ខ្យល់គ ឈ្លើងទាមវារមាស់មែនទែនតែនៅទ្រាំបានឯវាចាដាន ដូចគេយកដំបងមកគប់ចំបេះដូងវាឱ្យចុកចាប់



(អោយអញអៀវវាទៅរៀន ចុះជើងវាសំរាប់ធ្វើអី ? ហ៊ុះ ! ចង់ជិះលើអញផង ... បានជិះក៏ជិះចុះ អញរុកឆ្មៀលអោយយំរាល់ថ្ងៃ ទាល់តែណាណីម្តង) វាមិនឆ្លើយទេ វាងក់ក្បាលយល់ព្រម ។

ដានីសើចហើយនិយាយថា ÷

- ខ្ញុំដើររកសរសៃសក់ណាល្អិតមករីតវា !

អាព្រីងប្រកួកហៅគ្នីគ្នាឱ្យមកតំរង់ជួរ អោយដានីរើសសរសៃសក់ ពណ្ណរាយខ្មាសណាស់ រត់ទៅអែបនឹងគុម្ពោតព្រៃបាំងខ្លួន "មីតូចនេះវាឃើញអញទៅហើយ ... ហ៊ុស ! បើសិនជាអញបានធ្វើធំអី អញអោយគេលួចចាប់វាទៅសំរាតវិញម្តង ! យី ! បើអញធ្វើយ៉ាងនេះទាល់តែអោយវាធ្វើជាប្រពន្ធអញ តើអញត្រូវយកជាប្រពន្ធឬ ? ចុះបើវាសំដីធំម្លឹងៗ ថ្ងៃក្រោយវាច្បាស់ជានឹងក្លាយជាម៉ែប្រពន្ធ ដូចយាយត្រួតត្រាតាទៀតហើយ ! ថ្ងៃណាមានឱកាសអញឱ្យវាដោះខោអាវមើលវាម្តង !

ដានីមិនដឹងថាពណ្ណរាយកំពុងតែគុំគួនក្នុងចិត្តទេ នាងតូចដើរច្បូតសក់គេគ្រប់គ្នាដើម្បីរកសក់សរសៃស្វិត វាដកសក់ម្នាក់ ១០ សរសៃមកពិនិត្យ ហើយត្រីក្បាលមិនទាន់រកបានសោះ ទិយាយរួចវាទៅដកសក់អាមាប់និងអាខ្មៅ អាព្រីងទៀត ហើយត្រីក្បាលដដែល ។ អាមាប់ស្រែកដោយភ័យ ÷

- ចុះមានអាណាមិនទាន់ដកទេ ?

អ្ហូហ៍ ! ពណ្ណរាយទៅឯគុម្ពោតព្រៃឯណោះ! ដានីទៅដកសក់វាមើលក្រែងស្វិត !

- ទេ ! អោយគេចេញមក បើមិនចេញទេ ខ្ញុំអត់ជួយទេណា៎!

អាព្រីងប្រុងទៅទាញពណ្ណរាយចេញមក តែពណ្ណរាយអង្វរ ÷

- អាព្រីង អញមានកាំភ្លើងលេង ចាំអញអោយហ្វែងលេងដែរ ហ្វែងជួយអង្វរដានី ឱ្យវាចូលមកដកសក់អញទីនេះហើយ កុហកវាថា អញហត់ណាស់ ទើបនឹងងើបពីគ្រុន !

អាព្រីងឮយ៉ាងនេះក៏ទៅភូតដានី ÷

- អាពណ្ណរាយវាភ័យពេក ដើរលែងរួចហើយ មោះ ! ទៅដកសក់វា !

ដានីរកបានហើយសក់ស្វិត តែនាងចង់កាន់ក្បាលពណ្ណរាយលេង ទើបឆ្លើយថារកមិនបាន ។ ដានីដើរតាមព្រីងទៅរកពណ្ណរាយ ហើយជ្រាវក្បាលរកសក់ស្វិត ÷

- យី ! សក់អាប៊ុនេះផុយជាងគេ គ្មានក្បែលទេ គួរអោយចង់សើចណាស់ សក់នេះសរសៃទន់ហើយឆ្មារយកទៅធ្វើអីកើត ជាសក់រួញអង្គាសដីផង !

តែនាងតូចបែរជាឆ្លើយ ÷

- សក់នេះហើយត្រូវតាមផែនការ យកសក់ណាដែលវែង១យកទៅរឹត ហ៊ឹ ... សក់រួញយ៉ាងនេះពិបាករឹតណាស់ សុំស្ទាបក្បាលយូរបន្តិចហើយ !

ពណ្ណរាយធ្លាប់រមាស់ក្បាលពេលមានដៃវាលើ វាអាចទ្រាំបាន .... តែពេលនេះ ដានីជ្រាវសក់ក្បាល វាទ្រាំមិនបានសោះ វាអត់ដង្ហើមទំរាំដានីឈប់ជ្រាវ ។



(ហ៊ឹស ! សំដីមីតូចនេះក្អេងក្អាងណាស់ ទទេ១មកលេងក្បាលអញ ទៅផ្ទះវិញអោយយាយរំដោះគ្រោះចេញ)

ដានីបង្គាប់មកពណ្ណរាយថា ÷

- នែ៎ ! ក្មួយប្រុសម៉េចមិនរៀបចំខ្លួន ?

ពណ្ណរាយខឹងចង់ក្អួត (ហៅអញក្មួយប្រុសទៅហើយ អោយតែជីវិតអញនៅរស់ គង់តែមានថ្ងៃស៊ីសងគ្នាទៀតទេ !)

ពណ្ណរាយក៏ចោងហោងអោយដានីបេះឈ្លើង ។ ដានីក្លាហានណាស់មិនខ្លាចឈ្លើងទេ ចាស់១ជាច្រើនធ្លាប់ប្រើដានីរឿងនេះ ដូច្នេះកុមារីថ្មីកណាស់ ហើយតែងសាគួរថ្នាំជក់ក្នុងហោប៉ៅជានិច្ច ។ ការពន្លូតឈ្លើងចេញ ធ្វើឡើងដោយជោគជ័យ ឈាមបាញ់ចេញមកច្រើនតាមមាត់ឈ្លើង គ្រាន់តែថាមាត់ឈ្លើងចេញហើយ ពណ្ណរាយស្ទៀកខោភ្លាមដានីពេបមាត់ ÷

- ស្មោគគ្រោកមែន រកអីជូតឈាមចេញមិនគិតទេ គិតតែស្លៀកខោអោយឈាមប្រលាក់គគ្រិចណាស់ !

ពណ្ណរាយមិនតទេ វាស្លៀកខោរួចរត់ទៅផ្ទះភ្លាម លែងខ្វីសួរនាំនរណាទាំងអស់ គ្មាននរណាគិតគូរនឹងរឿងវាទេ រវល់តែជួយមើលអាម៉ាប់និងអាខ្មៅ ។ លុះយកឈ្លើងចេញអស់ហើយ ទាំងអស់គ្នាក៏សួររកពណ្ណរាយ ទើបដឹងថាបាត់ ។

ថ្ងៃកាន់តែខ្ពស់ ក្មេងទាំងនោះវាមិនបានទៅផ្ទះទេ បែរជានាំគ្នា

ទៅសាលារៀនវិញ ដើម្បីទៅរៀនល្ងាចមួយពេលទៀត អាម៉ាប់បាន អៀវដានី ហើយត្រឡប់មកវិញអាខ្មៅវ៉ាធានាអៀវជំនួសអាម៉ាប់ រីឯ អាព្រីងវ៉ាខឹងណាស់ ដោយពណ្ណរាយគេចខ្លួនមិនគោរពតាមពាក្យសន្យា ដែលវាបានយល់ព្រម ។ ទៅដល់សាលាឃើញពណ្ណរាយអង្គុយមុខថ្នាក់ ផ្លាស់ខោអាវថ្មីស្រឡាង ។ ពណ្ណរាយដើរមករកក្មេងៗទាំងនោះហើយ និយាយថា ÷

- អញខ្មាសដានីណាស់ ! ស្បៀកខោអាវប្រលាក់ឈាមអោយ ដានីដៀលថាស្មោគគ្រោក ! អញមិនយល់សោះ ហេតុអីដានីនៅក្មេងតែ វ៉ាមានប្រាជ្ញាលើសយើងធំៗបាន ? អញជំពាក់គុណដានីធំណាស់ ! អញ ក៏ត្រូវតែបំពេញតាមពាក្យសន្យា ដែលអញបានយល់ព្រមនឹងដានីដែរ តែអញសែនខ្មាសដានីណាស់ ព្រោះអញមិនដែលស្រាតឱ្យនរណាឃើញ សោះ ! គួរអីដានីវ៉ា .....

អាម៉ាប់ទះស្មាពណ្ណរាយ ÷

- នែ៎ ! អាចំកួត អញដើរស្រាតពីដើមភូមិដល់ចុងភូមិ មុជទឹក ភ្លៀងលេងរាល់ដង វាមិនដែលទៅជាស្អី ! សព្វបើរឿងអញ្ចឹងក៏ខ្មាស ដែរ កុំតែមានដានីចេះចាប់ឈ្លើង កុំអីអាឯងដេករោទិ៍មួយអាទិត្យ ឈ្លើងស៊ីឈាមអស់ងាប់ទៅជាខ្មោច .... ស្រាតវ៉ាយ៉ាប់ប៉ុណ្ណា ? កុំគេច វើយ ! ចេញទៅវិញអៀវដានី បើប្រកែកពួកយើងវ៉ាយអោយកប់ភក់ ម្តង !

- មិនប្រកែកទេ ចេញទៅវិញ អញអៀវមីល្អិតនោះហើយ !



សាសងគ្នាបានប៉ុណ្ណឹង ជួងបន្លឺជាសញ្ញាចូលថ្នាក់ ។ ពណ្ណរាយ ស្តាប់គ្រូពន្យល់មិនយល់សោះ ព្រោះវ៉ាខំរកមធ្យោបាយបែបណា ដើម្បី ផ្ចាញ់អោយដានីឈប់ជិះកវ៉ា វ៉ាគិតជាច្រើនសា ក៏រកឃើញមធ្យោបាយ វាញញឹមរីករាយ ឈប់ចងចិញ្ចើមទៀត .....

ឥឡូវដល់ពេលចេញទៅផ្ទះហើយ ពួកកុមារទាំងនោះនាំគ្នាហៅ ពណ្ណរាយឱ្យអៀវដានី តាមការចូលចិត្តរបស់នាងតូច ។ ពណ្ណរាយពុំតវ៉ា អ្វីទេ វ៉ាហុចខ្នងអោយដានីឡើងពីលើ ហើយដើរតិចៗរបៀបធូន់ៗ ដានី ស្រែកប្រាប់ទៅអាព្រីងថា ÷

- ព្រីងអើយ ! ចាំខ្ញុំផង មកជួយផ្លាស់ពណ្ណរាយនេះទៅ ដើរ ចង់ដួលហើយ !

ពណ្ណរាយប្រាប់ទៅដានីថា ÷

- បើចង់លឿនម៉េចមិនប្រាប់ខ្ញុំ? កុំបន្ទោសថាខ្ញុំរត់លឿនណា ! ហាំ ! តោងអោយជាប់ !

ដានីមិនទាន់ឆ្លើយផង ពណ្ណរាយរត់យ៉ាងលឿនវ៉ាគេវ៉ាឯង ទាំង អស់គ្នាឃើញដូច្នេះ ស្មានថាពណ្ណរាយប្រឡែងលេងជាមួយដានី ក៏សើច ក្អាកក្អាយ នាំគ្នាមើលពីក្រោយដោយមិនរត់តាមឡើយ ។ នាងតូច ស្រៀវខ្លួន ខំតោងយ៉ាងស្អិតទាល់តែពណ្ណរាយតឹងបំពង់កស្ទើរទ្រាំពុំបាន ប៉ុន្តែពណ្ណរាយមិនខ្វីឈប់ទេ វ៉ារត់ទាល់តែផុតឆ្ងាយពីគេធ្វើជាដួលទង្គិច នឹងដុំថ្ម ដួលជ្រុលទៅគុម្ពលំពាក់នៅក្បែរផ្លូវ អុកតូចទាំងជំហរទៅគុម្ព បន្លាលំពាក់ ធ្វើអោយដានីមុតសុសសាច់ ស្រែកយំតែម្តង ។ ជាមួយគ្នា

នោះ ជើងពណ្ណរាយក៏ចុកទាល់តែស្រក់ទឹកភ្នែក ដានីយំហ៊ូៗ ហើយជេរថា ÷

- អាក្មេងព្រហើន ! អញខំជួយវាពីរបីលើកហើយ វាគិតតែចង់ធ្វើបាបអញ ឯងនេះចំជាមនុស្សអាក្រក់ណាស់ គ្មានស្គាល់ល្អអាក្រក់អីទេ ធំតែអាយុតែចិត្តសាមាន្យដូចឆ្កែព្រៃ ហេតុអីក៏ឯងរត់ចូលគុម្ពលំពាក់នេះ ស្មានថាម្តាយមីងតូចឯងនេះភ្លើណាស់ឬ ? ឯងដឹងទេ យើងជាមនុស្សកើតពីរជាតិ យើងយល់រឿងធំៗច្រើនណាស់ ចូរឯងកុំប្រឡឹមបន្លំភ្នែកយើងណា ! ឯងដឹងទេ កាលពីជាតិមុនឯងជាក្មួយយើងណា ! នឹកឃើញថាឯងជាប់សាច់ឈាម យើងខំដេញក្របីនិងចាប់ឈ្លើងអោយឯង តើឯងសងគុណយើងរបៀបនេះឬ ?

ពណ្ណរាយដកបន្លាចេញពីជើង ហើយពោលទាំងអន់ចិត្តថា ÷

- យើងមានទៅចង់ចូលអី ! បើវាដួលទៅធ្វើម៉េចនឹងទប់ទាន់អូហ៎ ! ជាតិមុនឯងជាម្តាយមីងយើងទេ ស្តាយណាស់ដោយយើង មិនបានចាំជាតិដូចឯង ចុះបើឯងជាម្តាយមីងយើង ឯងដឹងទេជាតិមុនប្រពន្ធយើងឈ្មោះអី ? ឯប្តីរបស់ឯងជានរណា ? រួចវាយ៉ាងម៉េចបានជាឯងត្រូវស្លាប់មកកើតជាក្មេងតូចអាយុតិចជាងយើងទៅវិញ ?

ដានីឈឺខ្លួននឹងបន្លាលំពាក់ណាស់ វាចេះតែថាឱ្យតែខ្លួនវាធំជាងពណ្ណរាយ ។ កាលបើឮពណ្ណរាយចំអកអោយមកវិញ វាកាត់យល់ថា ÷

(" អាក្មេងប្រុសនេះវាឆ្លាតណាស់ វាសុខចិត្តឈឺសាច់ មិនព្រមអោយចាញ់ចិត្តទេ បើអញជិះវារាល់ថ្ងៃហើយដួលដូច្នេះ មុខអញច្បាស់



ជាកូតដាច់ ដល់ពេលធំទៅស្លាកស្នាម អស់អួតកើតហើយ") ដានីឆ្លើយទាំងខឹងថា ÷

- បើឯងភ្លេចហើយក៏ភ្លេចទៅ ! ចាំសួររកហេតុផលអី ប្រពន្ធឯងមិនចាំផង មកសួរគេទៀត ចុះកាលដែលឯងរៀបងាប់មានមកសួរយើងដែរ ? បើយើងអង្គុយចាំតែទាំងអស់នោះ ប្រហែលជាចាំចិត្តឯងឃោរឃៅយ៉ាងណាហើយ យើងច្បាស់ជាមិនព្រមមកជិះកឯង ហើយអោយឯងយកយើងមកក្រវាត់ចោលក្នុងគុម្ពលំពាក់ វេទនាដល់ថ្នាក់នេះទេ !

- យី ! ឯងអីក៏ពូកែដឹងម្ល៉េះ ? ឯងដឹងថាយើងក្មួយឯង ឯងមិនគួរណាភ្លេចយើង មិនស្គាល់ប្រពន្ធយើងនោះទេ ! តាមតាយើងប្រាប់ ថាយើងជាតិមុនមានប្រពន្ធអាយុច្រើនជាងយើងឆ្ងាយណាស់ ត្រូវជាម្តាយមីងយើងផង ប្រហែលជាឯងហើយដែលយើងបានផ្សង បើស្លាប់ទៅកើតជាតិណាៗ សូមអោយបានប្រពន្ធដដែល តែសូមអោយអាយុតិច ។ ឥឡូវឮឯងរំលឹករឿងជាតិមុន យើងជឿថាពិតជាឯងហើយ ជាអតីតប្រពន្ធយើង .... តើជាតិនេះឯងចង់ធ្វើប្រពន្ធយើងទៀតឬ ?

ដានីមិនយល់ថាប្តីប្រពន្ធគេរស់នៅដូចម្តេចទេ ប៉ុន្តែវាដឹងថាប្តីនិងប្រពន្ធត្រូវរស់នៅជាមួយគ្នា វាឆ្លើយមកវិញទាំងមួម៉ៅ ÷

- ពីជាតិមុនឯងផ្សងអញ្ចឹងមែនឬ ? ហ៊ឹះ ! កុំសង្ឃឹម ! ពីយប់មិញយើងយល់សប្តិអាក្រក់ណាស់ ថាមានយក្សមួយវាស្ទុះមកត្របាក់យើង ថ្ងៃនេះទើបយើងកាត់យល់ថា ក្នុងយល់សប្តិយប់មិញគឺឯងតែម្តង !

ពណ្ណរាយខំក្រោកទាំងត្រដរពីបន្ទាលំពាក់ ដោយឈឺនឹងបន្លាពេក វាស្ដាប់ចំលើយរបស់ដានីលែងឮ វាខ្សិបតែក្នុងពោះថា ÷

"អូយៗ... បើដឹងថាមុតបន្លាឈឺយ៉ាងនេះ មិនខ្ចីធ្វើដូលទេ.."

ដានីធើបមិនរួចឡើយ ណាជើងថ្លោះពីព្រឹកផង ណាលំពាក់ព័ទ្ធជុំវិញផង នាងតូចខឹងពេកស្រែកយំឮៗ ហើយធ្វើពុតជាស្រែកថា ÷

- អូយៗ ! ស្អីខាំឈឺណាស់ !

ពណ្ណរាយកាលបើឮថាស្អីខាំដានីវាភ័យដែរ វារត់ជាន់លំពាក់ទៅជួយក្រែងមានពស់ ឬសត្វពិសនានាខាំ ទោះបីស្អប់ដានីយ៉ាងណា ក៏វានៅមិនភ្លេចគុណដានីដែលបានជួយវាពីរដងដែរ ។ ដានីខ្ទប់ដៃទៅលើភ្លៅហើយធ្វើជាចុកណាស់ ។ ពណ្ណរាយលែងខ្វល់នឹងបន្លាមុត វាខំឆ្កាបន្លាពីខ្លួនដានីទាល់តែស្រលះ ហើយលូកដៃទៅទាញ រហូតមកដល់ក្រៅហើយសួរទៅដានីដោយភ័យថា ÷

- នែ៎ ! មីតូច .... ស្អីខាំ ?

- ហៅយើងថាម៉េចភ្លេចសន្យាហើយឬ ?

- ហៅឯងថាមីង វាអាចបាត់ឈឺឬ ? តើឯងចង់អោយយើងជួយឯងឬចង់អោយយើងហៅឯងថាម្ដាយមីងតូច ? ស្អីខាំម៉េចមិនបើកដៃចេញ ប្រយ័ត្នហួសពេលមើលជា !

- ស្រេចតែយើងៗមិនពឹងឯងមកជួយទេ !

- ចុះអម្បាញមិញ យើងជួយទាញឯងចេញពីបន្លា ម៉េចក៏ឯងព្រម ?



- ឯងជាអ្នករុញចូល ឯងត្រូវតែចាប់ទាញចេញអញ្ចឹងហើយ ជួយស្អី ? បើកុំតែឯង យើងក៏មិនវេទនាដល់អញ្ចឹងដែរ កោតឯងចេះសួររួច មុខសើចដូចស្វា !

- បើយើងដូចស្វា ឯងក៏ដូចស្វាដែរ ! ព្រោះឯងចូលគុម្ពលំពាក់ជាមួយយើង មនុស្សឆ្កួតណាអោយស្វានាំចូលគុម្ពលំពាក់បានទេ ទាល់តែស្វាដូចៗគ្នា បានវាចូលទៅរបូសទាំងអស់គ្នា ។ បើឯងព្រមធ្វើស្វាញីទៅ យើងមិនប្រកែកនឹងធ្វើស្វាឈ្មោលទេ !

ដានីមិនសូវយល់ពីបញ្ហាស្នេហា រវាងមនុស្សធំដូចពណ្ណរាយថាយ៉ាងនេះ វាដូចជាពុំដឹងអ្វីសោះ វាឆ្លើយមកវិញចាកប្រធាន ÷

- បើឯងទទួលថាស្វាហើយ គឺពិតជាអន់ជាងយើងហៅមិនឮ នេះមកពីយើងឈឺជើងពេក គេចមិនទាន់កុំអីយើងមិនឱ្យឯងក្រវាត់ចូលគុម្ពលំពាក់បានទេ ! ចូរឯងកុំស្មានថា យើងស្វាញីសោះឯងមើល នែ៎ ! រោមដៃរោមជើងយើងខ្លីៗ ស្ទើរតែមើលមិនឃើញ ឯងវិញដូចស្វាណាស់វែងៗ ....

និយាយដល់នេះ ស្រាប់តែស្អីទិចចង្កេះវាប៉ាត់ ចុកស្ទើរស្លាប់ ដានីខ្ទប់ភ្លៅស្រែកអូយៗ ឈឺណាស់ៗ !....

ពណ្ណរាយឃើញដានីយំមែនទែន វាកាន់តែស្លោភ្លេកមែនទែន ពណ្ណរាយស្ទុះទៅចាប់ ហើយសួរដោយថ្នមសំដីបន្តិចថា ÷

- នែ៎ ! ម៉ាក់មីងស្អីខាំ ?

- បែបខ្ទួយ ! អូហ៍ ! វារុលចូលហើយ ចូលក្នុងសំពត់ !

ពណ្ណរាយស្ទុះយ៉ាងលឿន រកមើលខ្ទុយតាមដៃដានីចង្អុល ទី បំផុតដោយភ័យពេក ដានីវាដោះសំពត់ក្រវាត់ចោលដើម្បីរកមើលខ្ទុយ សំពត់ហើរមកគ្របលើស្មាពណ្ណរាយ ធ្វើឱ្យវាភ្ញាក់ខ្លួនព្រើត "កម្មតាម ផន្ទាទាន់ហន់អញ្ចឹងទៅណាមីតូចឯង មិនទាល់ច្រកដូចអញ តែប៉ុណ្ណេះ រួចគ្នា !"

ដានីខ្លាចខ្ទុយទិចដៃ វាក៏ចង្អុលកន្លែងអោយពណ្ណរាយមើល ហើយវាស្រាតខោក្នុងរលាស់យ៉ាងលឿន អោយខ្ទុយធ្លាក់តែខ្ទុយមិន ធ្លាក់សោះ រិតតែខាំវាចុកសាជាថ្មី ។ ដានីយំយ៉ៃអោបពណ្ណរាយជាប់ ពណ្ណរាយដូចជាអាណិតនាងតូចដែរ វាឃើញខ្ទុយខាំ វាយករំពាត់វាយ ទំលាក់ហើយជាន់ពីលើយ៉ាងរហ័ស ខ្ទុយក៏ងាប់លែងកំរើក ។ ដានីត្រូវ ខ្ទុយទិចពីរកន្លែង វាទន់ខ្លួនដូចសំឡីយំតិចទៅៗ ហើយឈរលែងហ្នឹង ពណ្ណរាយភ័យកាន់តែខ្លាំង ស្រែកហៅអាឆ្លូញដែលដើរមកដល់អោយ ជួយ ។

- អាឆ្លូញ ជួយបងស្តេចឯងផង ! ខ្ទុយទិចទន់ខ្លួនអស់ហើយ!

អាឆ្លូញរត់មកយ៉ាងលឿន គ្មានសួរនាំអីទេ វាលើកដានីរត់មក ផ្ទះតាវង្សយ៉ាងលឿន ។ ទៅដល់ផ្ទះលោកវង្ស អាឆ្លូញស្រែកហៅតាំង ពីក្រៅ ÷

- លោកតាអើយ ! ជួយដានីផង ខ្ទុយទិច !

- យី ! ថ្ងៃមិញបាត់វាមិនឃើញមកបាយផ្ទះមួយពេល ពួគេ ថាជុំគ្នាក្បែរបឹង លុះឯងទៅតាមឃើញវាជុំគ្នាកំពុងតែស៊ីបាយ ក៏មិន



ហៅខ្លាចវាភ្ញាក់ផ្អើល ! ចុះឥឡូវម៉េចក៏ទៅជាខ្ទុយទិចទៅវិញ ? ពួក ឯងថ្ងៃមិញស៊ីបាយឯណា ? ម៉ែឪដើររកពេញតែភូមិ !

អាឆ្លូញឆ្លើយស្ទាក់ស្ទើរ ÷

- បាទ ! អត់មានស៊ីបាយទេ ... នាំគ្នា ....

លោកវង្សសើច ÷

- តាឃ្លោករត់រកបាយគាត់មកដល់ភូមិ តានិងតាពណ្ណរាយដើរ មកឃើញពួកឯងកំពុងតែព័ទ្ធវង់ជុំវិញបាយមួយល្អី អញស្តាប់ឮទាំងអស់ ខ្ជិលរំខានបាយពួកឯង អញក៏មកភូមិវិញយកកញ្ជើមួយ ដើរសុំបាយពី ម៉ែឪឯងរាល់គ្នា យកទៅសងតាឃ្លោកវិញ !

ដឹងថាលាក់លែងជិតហើយ អាឆ្លូញបួញមាត់អោយពណ្ណរាយ និយាយការពិត ។ ពណ្ណរាយក៏រៀបរាប់រឿងជំពាក់គុណដានីនិងសកម្ម-ភាពពួកវាហូរហែ ....

លោកវង្សស្តាប់ចប់ ហួសចិត្តនឹងក្មេងៗជាខ្លាំង គាត់ក៏អោយ ពណ្ណរាយដោះខោអាវបិទថ្នាំដែរ ស្រាប់តែឮមាត់ពួកកុមារមួយក្រុម មកដល់ ។ លោកវង្សមិនទាន់ចេញទៅទទួលផង អាដែងស្លៀកតែខោ អត់អាវ ស្ទុះព្រួមកដល់ភ្លាម ចំជាគ្មានគួរសមអីទេ អាខ្លួះអង្គុយក្បែរ គ្រែ សួរតាវង្សឡើងវិលក្បុង ។ ពេលនេះទើបពណ្ណរាយជឿថា ប្រជា-ប្រិយភាពរបស់ដានីសំបើមណាស់ មិនថាតែក្មេងៗទេ មនុស្សចាស់ៗជា ច្រើនក៏បានមកសួរសុខទុក្ខដានីដែរ (មីតូចនេះវាខុសគេយ៉ាងហ្នឹង បាន ជាសំដីឡូយម្ល៉េះ ?) ជីតាពណ្ណរាយក៏មកជួយសំរួលហេតុនានា ហើយ

ក៏នាំគ្នាយកទៅព្យាបាលរបួសឯផ្ទះបាត់ទៅ ។

..................................................

ពេលវេលាបានរំលងទៅជាលំដាប់ ដានីក៏ចំរើនវ័យធំឡើងជាលំដាប់ ។ លោកវង្សមានបំណងថា កាលណាដានីមានអាយុ ១០ ឆ្នាំ ទើបគាត់បញ្ជូនឱ្យទៅរៀននៅប្រទេសជប៉ុន តាមផែនការរបស់គាត់គ្រោងទុក ប៉ុន្តែ ៦ ឆ្នាំកន្លងមកនេះ មុនី-ពិសិដ្ឋនរៈគ្មានកូនចៅតទៅទៀតសោះ ធ្វើអោយតាវង្សមានការព្រួយបារម្ភក្នុងចិត្ត ខ្លាចពិសិដ្ឋនរៈនិងមុនីគេបំភ្លេចពាក្យសន្យា ហើយមកទាមទារយកដានីទៅវិញ ដូច្នេះលោកវង្សក៏សំរេចចិត្តថា នឹងបញ្ជូនដានីទៅរៀននៅប្រទេសជប៉ុនតាំងពីដានីអាយុ ៧ ឆ្នាំអោយហើយទៅ គាត់មានបងធម៌ម្នាក់ដែលធ្លាប់ទាក់ទងគ្នាផ្នែកជំនួញនៅជប៉ុនឯណោះ ហេតុនេះគាត់បានផ្ញើសំបុត្រឱ្យបងធម៌គាត់មកទទួលដានីនៅឯស្រុកថៃ យកទៅរៀនវិជ្ជាតុបតែងផ្ទះរៀបចំការនិងធ្វើមេផ្ទះអោយបានសមដូចបំណង ។

មួយឆ្នាំកន្លងមកនេះ ដានីបានឈានអាយុពី ៦ ឆ្នាំចូល ៧ ឆ្នាំ ហើយគ្មាននរណាដឹងថាលោកវង្សជាជីតាដានីទេ ហើយក៏គ្មាននរណាម្នាក់អាចដឹងអំពីសាវតាប្រវត្តិម្តាយឪពុករបស់ដានីដែរ ។ គេនាំគ្នាហៅដានីថាកូនលោកវង្ស ហើយលោកវង្សក៏លាក់រឿងយ៉ាងជិត មិនប្រាប់នរណាដែរ គាត់ព្យាយាមនៅចិញ្ចឹមចៅ ដោយពុំមានទៅជិតក្បែរកូនប្រុសនិងកូនប្រសាឡើយ ។ រីឯមុនីនិងពិសិដ្ឋនរៈ កាលបើឪពុកមិនមកជិតដូច្នេះក៏មិនហ៊ានទៅអើតដែរ ព្រោះគេដឹងថាគាត់ធ្វើយ៉ាងនេះ មកពី



ចង់ហួងហែងយកចៅគាត់ និងមិនចង់អោយដឹងថា ម៉ែវាលេងកុន ។ ចំពោះដានីនិងពណ្ណរាយ តើយ៉ាងម៉េចដែរ ? វាទាំងពីរនៅតែតំលើងផ្ទុងដាក់គ្នារហូត ។ ដើម្បីឱ្យឈ្នះប្រជាប្រិយភាពរបស់ដានី ពណ្ណរាយបានអោយជីតាវាទៅទិញល្បែងប្លែកៗពីទីក្រុងយ៉ាងច្រើន យកមកចែកក្មេងៗក្នុងភូមិអោយគេស្រលាញ់វា ។ វានឹកឆ្ងល់ថា តាំងពីថ្ងៃដួលនោះមក ដានីមិនដែលសងសឹកនឹងវាសោះ ការពិតដានីព្រួយចិត្តព្រោះជីតាឬប៉ាវាប្រាប់ថា ប្រុងអោយវាទៅរៀនស្រុកគេ វានឹកមិត្តៗ វានឹកស្តាយបុណ្យសក្តិវានៅក្នុងភូមិ ដែលគេតំលើងអោយធំ ប្រសិនបើទៅទីផ្សេងវិញ វាមានអំណាចដូចនៅក្នុងភូមិដែរឬ ? ដានីមុខស្រពោន ហើយវាខ្ជិលគិតរឿងពណ្ណរាយណាស់ ព្រោះគង់តែបែកគ្នា ក្នុងថ្ងៃណាមួយមិនខាន ។ ផ្ទុយពីដានី ពណ្ណរាយតាមដានសកម្មភាពដានីជានិច្ច វាសួរតាវានៅយប់មួយ ក៏បានដឹងថាដានីជិតឈប់នៅភូមិនេះទៀតហើយ វាភ្ញាក់សែនភ្ញាក់ វាស្អប់ដានីដោយពូកែអួត តែវាដូចជាស្តាយអ្វី នៅពេលឮថាដានីលែងនៅភូមិនេះតទៅទៀត ។ ស្អែកនេះបងធម៌របស់គាត់មកទទួលយកដានីហើយ លោកវង្សប្រាប់អាស័យដ្ឋានរបស់គាត់ ឱ្យលោកយូកូរីម៉ាបានដឹងដែរ ដើម្បីផ្ទេរដានីអោយទៅសិក្សា ។ ចាស់ទុំកំពុងជជែកគ្នា ក្មេងៗនាំគ្នាលេងស្តេចចង់នៅឯវាលក្នុងភូមិ ។

ដានីឈប់ធ្វើស្តេចហើយ វាអង្គុយសំកុកកើតទុក្ខ គេធ្វើស្តេចជំនួសវា វាដុះគំនិតចង់ធ្វើតួរាយរងនឹងគេ ហើយចង់ដឹងថា តើនរណាចូលចិត្តវាខ្លះ ? បើគេចូលចិត្តវា គេនឹងខ្សិបស្រលាញ់វាហើយ ។ កុមារ

ក្នុងភូមិតើនរណាស្អប់ដានី ? គ្មានទេ ! ដូច្នេះមួយណាចូលមកក៏ឱ្យបថា ស្រលាញ់ដានីដែរ ស្រីៗទាយត្រូវរហូត។ គេលាក់ដានីទុក ហើយអោយអ្នកផ្សេងឡើងជំនួស ថ្វីបើចាញ់បែបនេះហើយ ក៏ពួកប្រុសៗនៅតែឱ្យបថាស្រលាញ់ដានីដដែល ព្រោះអ្នកធ្វើស្តេចនោះភ្នែកវាមិនរឹងសោះ វាចេះតែក្រលេកមើលមុខដានី ធ្វើអោយគេចាប់ថ្នាក់បាន ។ ដោយគ្មាននរណាហ៊ានស្រលាញ់នារីផ្សេង គេក៏ច្រានពណ្ណរាយអោយទៅឱ្យបម្តង ព្រោះគេគ្រប់គ្នាដឹងថា ពណ្ណរាយហ៊ានស្អប់ដានី មុខជាមិនហ៊ានឱ្យបថាស្រលាញ់ដានីទេ ។ តើពណ្ណរាយវាឱ្យបថាម៉េចដែរ ?

- អាចក់ ! អាស្តេចភ្លើ កុំមើលដានីអោយសោះ មើលទៅចុងឈើឮទេ ? អញស្រលាញ់ដានីណាស់ ! ៧ ឆ្នាំក្រោយអញតាមស្រលាញ់ដានីយកធ្វើប្រពន្ធអោយបាន !

អាចក់ភ្ញាក់ព្រើត ហើយខំមើលឡើងទៅលើធ្វើឱ្យស្រីៗសង្ស័យហើយសួរពីម្នាក់ទៅម្នាក់ ។ រាល់យប់ពណ្ណរាយមិនដែលឡើងឱ្យបទេ វាអង្គុយលើមែកឈើមើលគេលេង ដូច្នេះមិនដឹងចិត្តវាស្រលាញ់អ្នកណា ? តែបើដានីវិញជាគូរបស់វាហើយ អោយដានីឡើងទៅមិនអីទេ ។ ដានីដូចជាភ្លេចខ្លួនដែរ ឃើញអាចក់ឈប់មើលមកវាៗ ក៏យល់ថាពណ្ណរាយមិនស្រលាញ់វាហើយក៏ដើរទៅរកស្តេច ក្រុមប្រុសៗហ៊ោគ្រេវ ។

- ពណ្ណរាយឱ្យបថាស្រលាញ់ដានីដែរ ! ហាស់ ! ហាស់ ! បងស្តេចអើយ មុននឹងបែកគ្នាសុំច្រៀងពីរបីបទមក !

ពណ្ណរាយស្រែកកាត់ ÷



- អ្នកចាញ់អៀវអញម្តងរ៉ឺយ !

ស្តេចចង់ក៏ប្រកាសឡើងថា ÷

- អាពណ្ណរាយវាឱ្យបថា វាស្រលាញ់ដានីណាស់ ! វាថាតាមយកធ្វើប្រពន្ធអោយបាន ! ចុះបើបងស្តេចយើងស្អែកនេះជិះយន្តហោះទៅស្រុកអីគេនោះទៅហើយ តើវាប្រុងជិះអីទៅតាម ?

ពណ្ណរាយរួញខ្លួន កាលបើឮអាចក់ប្រកាសខ្លាំងៗដូច្នេះ "អាចំកួតអញ្ចឹងក៏ស្រែកឮៗដែរ !" ។

ពាក្យអាចក់និយាយខ្លាំងៗទាំងនោះ ធ្វើឱ្យដានីឆ្ងល់ណាស់ តើអាក្មេងនេះវាចង់ឈ្នះ ឬក៏ចិត្តវាចង់យ៉ាងនេះមែន ?

ស្អែកឡើងពេលដានីចេញដំណើរ គេឃើញកុមារជាច្រើនជួយហែហមបាត់តែពណ្ណរាយមួយទេ តើពណ្ណរាយវាទៅណា ? វាឈរពីក្រោមដើមស្វាយមួយដើមដែលវានិងដានីឈ្លោះគ្នាដំបូង ក្រុមធ្វើដំនើរក៏ដើរជូនដានីមកក្បែរគល់ស្វាយ ព្រោះរថយន្តលោកយូកូរីម៉ាចតនៅទីនោះ ។ ដានីភ្ញាក់ណាស់ ពេលឃើញពណ្ណរាយនៅទីនោះ សំដីរបស់ពណ្ណរាយឱ្យបពីយប់មិញធ្វើឱ្យនាងតូចទន្ទេញជាប់មាត់ "អញស្រលាញ់ដានីណាស់ អញដណ្តឹងដានីធ្វើប្រពន្ធអោយបាន !" ពណ្ណរាយដើរចេញពីក្រោយគល់ស្វាយ ដានីមើលមុខវា ពណ្ណរាយហុចក្រដាសមួយផ្ទាំងអោយមកដានី.... ទាំងអស់គ្នាឆ្ងល់ណាស់ ចុះពណ្ណរាយឱ្យអីទៅដានី ? ដោយមិនដឹងខ្លួនមុន ដានីគ្មានអ្វីឱ្យទៅពណ្ណរាយវិញសោះ ពណ្ណរាយញញឹមស្ងួតដាក់ដានីហើយវាឱ្យបតិចៗល្មមតែដានីឮ ( ដានីខ្ញុំនឹកដានីឯង

ណាស់ !) ដានីបង្ហាញមុខមិនពេញចិត្ត ពណ្ណរាយក៏បន្ថែមពាក្យ (អ្នកមីងដើរទៅឆ្ងាយនឹកដល់ថ្ងៃខ្ទួយទិចផង !) បានពណ្ណរាយហៅមីង ដានីពេញចិត្តភ្លាម នាងតូចសើចស្នាញដាក់ពណ្ណរាយ ហើយលើកដៃលាទាំងអស់គ្នា ។ ពណ្ណរាយមុខជូរជាងគេ ឱ ! ដានី ! ពណ្ណរាយប្ដេជ្ញាថាយកដានីធ្វើប្រពន្ធអោយបាន ដើម្បីសងជំងឺចិត្ត ដែលដានីអាចស្រោតខោពណ្ណរាយបាន ។